ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ០១៦ សព្រក

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីការផ្អាកដំណើរការច្រកទ្វារព្រំដែនកម្ពុជា-ថៃ

យោងលើការវិវត្តនៃស្ថានភាពព្រំដែន ដែលភាគីថៃបានកំពុងឈ្លានពានដែនអធិបតេយ្យកម្ពុជា ដោយវាយប្រហារតាមគ្រប់ទម្រង់មិនរើសគោលដៅ បណ្តាលឱ្យប្រជាជនកម្ពុជាស្លាប់ និងរបួស ព្រមទាំងប៉ះពាល់ដល់ភូមិឋានប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត **ក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលកម្ពុជា** សូមជម្រាបជូនសាធារណជនជាតិ និងអន្តរជាតិជ្រាបថា រាជរដ្ឋាភិបាលកម្ពុជាសម្រេចផ្អាកការធ្វើដំណើរចេញ-ចូលទាំងស្រុងនៅតាមច្រកទ្វារព្រំដែនកម្ពុជា-ថៃ ចាប់ពីពេលនេះតទៅ រហូតដល់មានការជូនដំណឹងជាថ្មី។ ការសម្រេចនេះ គឺដើម្បីធានាសុវត្ថិភាពប្រពលរដ្ឋកម្ពុជា និងប្រជាពលរដ្ឋថៃ ព្រមទាំងជនបរទេសគ្រប់ជាតិសាសន៍ពីគ្រោះថ្នាក់ពេលធ្វើដំណើរ ជាពិសេសការធ្វើដំណើរឆ្លងកាត់ព្រំដែន។

ក្នុងន័យនេះ ប្រជាពលរដ្ឋកម្ពុជាដែលកំពុងស្ថិតក្នុងព្រះរាជាណាចក្រថៃត្រូវបន្តរស់នៅ និងធ្វើការក្នុងប្រទេសថៃ ជាធម្មតា។ ដូចគ្នាដែរ ប្រជាពលរដ្ឋថៃដែលកំពុងរស់នៅ និងធ្វើការក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបន្តស្ថិតនៅកម្ពុជា ជាធម្មតាដែរ រហូតបទឈប់បាញ់ត្រូវបានអនុវត្តពេញលេញ។ វិធានការនេះ គឺដើម្បីធានាសុវត្ថិភាពប្រជាពលរដ្ឋកម្ពុជានិងប្រជាពលរដ្ឋថៃកុំឱ្យមានគ្រោះថ្នាក់ពេលធ្វើដំណើរ ពិសេសការឆ្លងកាត់តាមព្រំដែន។

**ក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលកម្ពុជា** បានណែនាំរដ្ឋបាលខេត្តជាប់ព្រំដែន និងអាជ្ញាធរគ្រប់រាជធានី-ខេត្ត បង្កើនការយកចិត្តទុកដាក់ផ្តល់ការគាំពារគ្រប់បែបយ៉ាងអស់ពីលទ្ធភាពដល់ប្រជាពលរដ្ឋថៃ និងជនបរទេសទាំងឡាយ ទាំងអ្នករស់នៅតំបន់ព្រំដែន និងទូទាំងប្រទេស ឱ្យបានដូចគ្នានឹងប្រជាពលរដ្ឋកម្ពុជាដែរ។ ជាមួយគ្នានេះ **ក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលកម្ពុជា** ស្នើ **ក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលថៃ** ផ្តល់ការគាំពារដល់ប្រជាពលរដ្ឋកម្ពុជា ដែលកំពុងរស់នៅក្នុងប្រទេសថៃ ដូចគ្នាដែរ។

អាស្រ័យហេតុនេះ សូមសាធារណជនជាតិ និងអន្តរជាតិជ្រាប។

ថ្ងៃសៅរ៍ ៤ រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ ៦ ឆ្នាំ២០២៥

*Unofficial Translation*

**Press Release**
**Suspension of Operations at Cambodia–Thailand Border Crossings**

In light of recent developments along the border, during which the Thai side has committed acts of aggression against Cambodia's sovereignty through indiscriminate attacks, resulting in Cambodian civilian casualties and injuries, as well as damage to residential areas and physical infrastructure, **the Ministry of Interior of the Royal Government of Cambodia** hereby informs the national and international public that the Royal Government of Cambodia has decided to fully suspend all entry and exit movements at all Cambodia–Thailand border crossings, effective immediately and until further notice. This decision has been taken to ensure the safety and security of Cambodian citizens, Thai nationals, and foreign nationals of all nationalities, particularly those traveling across the border.

In this regard, Cambodian citizens currently residing and working in the Kingdom of Thailand are advised to continue living and working there as normal. Likewise, Thai nationals currently residing and working in the Kingdom of Cambodia are advised to remain in Cambodia as usual, until the ceasefire is fully implemented. This measure aims to prevent risks and ensure the safety of civilians, especially with respect to cross-border travel.

**The Ministry of Interior of the Royal Government of Cambodia** has instructed provincial administrations along the border, as well as authorities of all capital and provincial administrations nationwide, to enhance attention and provide maximum protection and assistance, within their capacity, to Thai nationals and foreign residents—both in border areas and throughout the country—on an equal basis with Cambodian citizens. At the same time, the **Ministry of Interior of the Royal Government of Cambodia** respectfully calls upon the **Ministry of Interior of the Royal Government of Thailand** to provide appropriate protection to Cambodian citizens currently residing in Thailand.

Accordingly, the national and international community are hereby informed.

Phnom Penh, December 13, 2025